ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១១៧
ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩
សាលដីកា
លេខ: ៧២ (I)
ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០

# សាលដីកា
# តាមនាមប្រជារាស្ត្រខ្មែរ
# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រមរបាយការណ៍

៥.លោកស្រី [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

នៅលើបណ្តឹងសាទុក្ខលេខ ៨៦ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សេត ប្តឹងមិនសុខចិត្តនិងសាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រIV "វន" ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមាន៖

## ជនជាប់ចោទ:

១-ឈ្មោះ [redacted] សេត ហៅ នួន ភេទប្រុស អាយុ៥០ឆ្នាំ សញ្ជាតិខ្មែរ-ឥស្លាម មុខរបរស៊ីឈ្នួលកាប់ព្រៃ កៅស៊ូ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅ [redacted]

Scanned with CamScanner

[redacted] ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] "វ" មានកូនចំនួន ០៦ នាក់ ជាទីតិជន ទោសពីមុនគ្មាន ។ (អ្នកប្តឹងសាទុក្ខ)

មេធាវីការពារសិទ្ធិលោក [redacted] សុខុន

២-ឈ្មោះ [redacted] មីន ភេទប្រុស អាយុ៥៣ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តត្បូងឃ្មុំ ជាទីតិជន។ (ក្រៅឃុំ)

**ជាប់ចោទពីបទ** កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធិ ប្រព្រឹត្ត នៅចំណុចអូរស្ទឹងក្រូច ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៦២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

**អំពីអង្គហេតុ:**

កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ កម្លាំងមន្ត្រីឧទ្យានុរក្ស បានធ្វើការចុះល្បាតទប់ស្កាត់ បង្ក្រាបបទល្មើស ក្នុងតំបន់ដែនជំរកសត្វព្រៃ ព្រៃឡង់ក្នុងភូមិសាស្ត្រខេត្តក្រចេះ បានចុះដល់ចំណុច អូរស្ទឹងក្រូច ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ ហើយបានឃាត់ខ្លួនជនសង្ស័យម្នាក់ឈ្មោះ [redacted] សេត ហៅ ឡូន ភេទប្រុស អាយុ៥០ឆ្នាំ មានទីលំនៅភូមិគីឡូបី ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កំពុងធ្វើសកម្មភាពកាប់រានព្រៃធ្វើជាកម្មសិទ្ធិ កម្លាំងមន្ត្រីឧទ្យានុរក្សធ្វើការចាប់ឃាត់ខ្លួន និងដកហូតបានម៉ាស៊ីន (ត្រង់ស៊ីនី) ចំនួន ០១, កាំបិតចំនួន ០១ និងពូថៅចំនួន០១។ ក្រោយពេលសួរចម្លើយឈ្មោះ [redacted] សេត ភេទប្រុស រួច ឈ្មោះនេះបានឆ្លើយសារភាពដីដែលខ្លួនបានកាប់នោះគឺ ទិញពីឈ្មោះ ឡឿន ភេទប្រុស, ឈ្មោះ [redacted] មីន ភេទប្រុស និងឈ្មោះ ណូ ភេទប្រុស ដោយឈ្មោះ ឡឿន បានអះអាងថា ដីសម្បទាដែលបម្រុងនឹងបង្កើតភូមិនៅទីនោះហើយឈ្មោះ ម៉ាស់ ភេទស្រី ក៏បានទិញដីពីឈ្មោះ ឡឿន ភេទប្រុស,ឈ្មោះ [redacted] មីន ភេទប្រុស និងឈ្មោះ ណូ ភេទប្រុស ដែរ ហើយបានជួលឈ្មោះ [redacted] សេត ហៅ ឡូន ឱ្យកាប់រានដីព្រៃឲ្យទើបសមត្ថកិច្ចចាប់ឃាត់តែម្តង ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៦ "ឃ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តក្រចេះ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ក.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សេត ហៅ ឡូន ភេទប្រុស អាយុ៥០ឆ្នាំ ដែលមានសាវតាជាតិខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ៦(ប្រាំមួយ) ឆ្នាំ។

Scanned with CamScanner

១.ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] មីន ភេទប្រុស អាយុ៥៣ឆ្នាំ ដែលមានសាវតាជាតិខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ៦(ប្រាំមួយ) ឆ្នាំ។

ពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅចំណុចអូរស្ទឹងក្រូច ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៦២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

២.ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] មីន ភេទប្រុស អាយុ៥៣ឆ្នាំ ដែលមានសាវតាជាតិខាងលើ យកមកផ្តន្ទាទោស តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.វត្ថុតាងដែលចាប់យកមាន រណារយន្តគ្រង់ស៊ីទីចុនតូច ចំនួន០១គ្រឿង, ពូថៅចំនួន ០១ និងកាំបិតផ្គាក់ចំនួន០១ ត្រូវរឹបអូសបំផ្លាញចោល។

៤.សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សេត ហៅ ទូន និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] មីន ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៥ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សេត ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៦ “ឃ” ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តក្រចេះ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រIVវន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៥ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] សេត ហៅ ទូន ទុកជាត្រឹមត្រូវ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៦ “ឃ” ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តក្រចេះ ទុកជាបានការ លើកលែងចំណុចទី ១.ក. ដែលសម្រេចថា “ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សេត ហៅ ទូន ភេទប្រុស អាយុ៥០ឆ្នាំ ដែលមានសាវតាជាតិខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ៦ (ប្រាំមួយ) ឆ្នាំ” ត្រូវកែប្រែមកជា “ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សេត ហៅ ទូន ភេទប្រុស អាយុ៥០ឆ្នាំ ដែលមានសាវតាជាតិខាងលើ ដាក់ពន្ធនាគារកំណត់រយៈពេល ៥(ប្រាំ) ឆ្នាំ” វិញ ក្រៅពីចំណុចនេះត្រូវរក្សាទុកជាបានការដដែល។

៣.បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

Scanned with CamScanner

៤.សាលដីកាផងដឹងជម្រះ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ភេទ, មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩។ ទុកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ របស់ឈ្មោះ [redacted] ភេទ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

ជនជាប់ចោទដែលជាម្ចាស់បណ្តឹងសាទុក្ខ បានសារភាពនូវអំពីសកម្មភាពរបស់ខ្លួនដែលបានប្រព្រឹត្តកាប់គាស់រុករានដីព្រៃភ្នំ ដុតនិង ឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ ផ្ទាល់ខ្លួនដែលល្មើសនឹងច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ យោងតាមមាត្រា ៥៦ និងមាត្រា ៦២ ដែលតម្រូវដាក់ទណ្ឌកម្មដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ១០ឆ្នាំ។ ដូចនៅក្នុងសំអាងហេតុដែលបានបង្ហាញចំនុច ២,៣,៤ នៃសាលដីការបស់សាលាឧទ្ធរណ៍ស្រាប់ ដូចនេះសាលាឧទ្ធរណ៍បានសម្រេចផ្តន្ទាទោសបន្ថយទណ្ឌកម្ម ពី៦(ប្រាំមួយ)ឆ្នាំ មក ៥(ប្រាំ)ឆ្នាំ វិញនោះគឺកម្រិតអប្បរមារួចហើយ។

## <u>តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជំរះសម្រេច</u>

១-ទទួលបណ្តឹងសាទុក្ខលេខ ៨៦ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ភេទ ទុកជាត្រឹមត្រូវតាមទម្រង់ តែផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រIVរន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

+លោកមេធាវី [redacted] សុខន ការពារជនជាប់ចោទឈ្មោះ [redacted] ភេទ ធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្ញុំជាជនជាតិខ្មែរ ឥស្លាម គាត់ត្រូវបានសាលាដំបូងផ្តន្ទាទោស៦ឆ្នាំ គាត់មិនសុខចិត្តប្តឹងឧទ្ធរណ៍កាត់នៅសល់៥ឆ្នាំ ទើបអត់សុខចិត្តប្តឹងសាទុក្ខមកតុលាការកំពូល។

ដើមហេតុកូនក្តីខ្ញុំគឺស៊ីឈ្នួលកាប់ឆ្ការព្រៃអោយគេហើយបច្ចុប្បន្នដីនៅត្រង់ចំណុចនោះ ត្រូវបានអាជ្ញាធររាជរដ្ឋាភិបាលបានបង្កើតទៅជាភូមិ ឃុំ ស្រុកហើយពលរដ្ឋមករស់នៅលើទីតាំងនោះរួចហើយ។ តាមមាត្រា៤ នៃក្រមព្រហ្មទណ្ឌ ពុំមានបទល្មើសទេប្រសិនបើគ្មានចេតនាប្រព្រឹត្ត ដូច្នេះកូនក្តីខ្ញុំគ្មានកំហុសទេសុំលើកលែងចោទប្រកាន់។

Scanned with CamScanner

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់អំណានលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៨៦ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សេត ហៅ ទូន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្ដីនេះយកមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧, មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា សេចក្ដីសន្និដ្ឋានផ្ទាល់មាត់របស់តំណាងមហាអយ្យការអមតុលាការកំពូលនាពេលសវនាការ មានខ្លឹមសារប្រហាក់ប្រហែលគ្នាទៅនឹងសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ខ្លួនដែរថា បណ្ដឹងសាទុក្ខលេខ ៨៦ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សេត ប្ដឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រ.វ.ទ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់។ តុលាការកំពូលអាចលើកយករឿងក្ដីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការនោះ និងបទប្បញ្ញត្តិមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះ គឺស្របគ្នាទៅនឹងផ្នែកសំអាងហេតុត្រង់ចំណុចទី១ ខាងលើនេះ របស់តុលាការកំពូលដែរ ។

៣-យល់ឃើញថា សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងនូវអំណះអំណាងរបស់ខ្លួនថា ជនជាប់ចោទឈ្មោះ [redacted] សេត បានឆ្លើយសារភាពអំពីអំពើរបស់ខ្លួនថា ខ្លួនពិតជាបានកាប់គាស់ រុករានដីព្រៃ កាប់ឆ្ការ ដុត ឈូសឆាយដីព្រៃ ដើម្បីយកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ដែលល្មើសនឹងច្បាប់ស្ដីពីតំបន់ការពារ ធម្មជាតិ យោងតាមបទប្បញ្ញត្តិមាត្រា ៥៦ និងមាត្រា ៦២ ដែលត្រូវដាក់ពន្ធនាគារកំណត់ពី ៥ ឆ្នាំ ទៅ ១០ ឆ្នាំ ដូចមានលើកឡើងបង្ហាញក្នុងផ្នែកសំអាងហេតុចំណុចទី២ ,ទី៣ និងទី៤ នៃសាលដីការបស់សាលាឧទ្ធរណ៍ស្រាប់ ។ ការដែលសាលាឧទ្ធរណ៍(ភ្នំពេញ) បានសម្រេចកែប្រែកម្រិតទណ្ឌកម្មពី ៦ ឆ្នាំ មកនៅត្រឹមកម្រិត ៥ ឆ្នាំវិញនោះ គឺជាកម្រិត អប្បបរមាហើយ និងប្ដឹងសុំឱ្យតុលាការកំពូលបដិសេធបណ្ដឹងសាទុក្ខលេខ៨៦ ចុះថ្ងៃទី

Scanned with CamScanner

០៣ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សេត ដែលប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រ.ពវន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ និងប្តឹងសុំតម្កល់នូវសាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រ.ពវន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការនោះ គឺជាសេចក្តីសន្និដ្ឋាន និងជាការប្តឹងសុំមានមូលដ្ឋានសំអាងហេតុលើអង្គហេតុ ភស្តុតាង អង្គច្បាប់សមស្របហើយ ។

៤-យល់ឃើញថា សេចក្តីបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] សេត ហៅ ទូន ដែលបានអះអាងថា ការដែលខ្លួនបានកាប់គាស់ រុករានដីព្រៃ កាប់ឆ្ការ ដុត ឈូសឆាយដីព្រៃ ក្នុងអង្គហេតុដែលខ្លួនត្រូវបានតុលាការអង្គហេតុសម្រេចនិងប្រកាសទោសលើខ្លួនកំណត់ដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ នោះ គឺខ្លួនស៊ីឈ្នួលកាប់ឆ្ការព្រៃឱ្យគេទេ ហើយបច្ចុប្បន្ននេះ ដីនៅត្រង់ចំណុចនោះ ត្រូវបានអាជ្ញាធររាជរដ្ឋាភិបាលបានបង្កើតទៅជាភូមិ ឃុំ ស្រុក ហើយពលរដ្ឋបានមករស់នៅលើទីតាំងដីនោះរួចហើយ ។ យោងតាមបទប្បញ្ញត្តិមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ *"ពុំមានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត"* ដូច្នេះ ខ្លួនគ្មានកំហុសទេ ខ្លួនសុំបានរួចខ្លួនពីបទចោទប្រកាន់ ។ រីឯ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ ក៏បានធ្វើសេចក្តីសន្និដ្ឋានស្ទើរដូចគ្នាបេះបិតទៅនឹងខ្លឹមសារនៃសេចក្តីបញ្ជាក់អំពីមូលហេតុបណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] សេត ហៅ ទូន ដែរនោះ ដោយមិនមានលើកឡើងនូវអង្គហេតុដែលមានបម្រែបម្រួលថ្មីនេះ ដែលមានបញ្ជាក់ដោយភស្តុតាង ឬជាឯកសារផ្លូវការណាមួយ ដែលអាចឱ្យតុលាការកំពូលជឿបានឡើយ។

៥-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ភ្នំពេញបានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងខេត្តក្រចេះលេខ ០៦ "ឃ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ ទុកជាបានការ គ្រាន់តែបានកែប្រែកម្រិតទណ្ឌកម្មដោយបន្ថយមកនៅត្រឹមទោសដាក់ពន្ធនាគារកំណត់ ៥ (ប្រាំ) ឆ្នាំវិញ ពីបទកាប់គាស់ រុករានដីព្រៃ កាប់ឆ្ការ ដុត និងឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិ តាមបទប្បញ្ញត្តិមាត្រា៥៦ និងមាត្រា ៦២ កថាខណ្ឌទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិនេះ ជាការត្រឹមត្រូវហើយ ព្រោះថាជនជាប់ចោទ [redacted] សេត ហៅ ទូន ត្រូវបានមន្ត្រីនគរបាលយុត្តិធម៌ចាប់ខ្លួនបាននៅក្នុងខណៈពេលកំពុងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង គឺជាសេចក្តីសម្រេចដោយមានមូលដ្ឋានសំអាងហេតុលើអង្គហេតុ ភស្តុតាង អង្គច្បាប់ សមស្របហើយ ។

៦-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៨៦ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទ [redacted] សេត ហៅ ទូន មិនមានមូលហេតុបណ្តឹងសាទុក្ខ សមស្របតាមបទប្បញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ ។

៧-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រ.ពវន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ហើយ ។

Scanned with CamScanner

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធបណ្តឹងសាទុក្ខលេខ ៨៦ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សេត ហៅ ទូន ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២១ ក្រIVវន ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី១៣ ខែមីនា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០២០ ។

Scanned with CamScanner